00500275

**Declassified to Public**
**28 October 2021**

D1/1

**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៣/២០-១១-២០០៨-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី |
| **ភាសាដើម** | : | ភាសាអង់គ្លេស |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 09 / 2009
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីជូនដំណឹងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី**
**អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី:** | **ការិយាល័យសហចៅក្រមស៊ើបអង្កេត:** | **សហព្រះរាជអាជ្ញាជាតិ:** |
| លោក William SMITH | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| | ចៅក្រម Marcel LEMONDE | |

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

# សេចក្ដីជូនដំណឹង

១. ដោយអនុលោមតាមវិធាន ៥៣ និងអនុវិធាន ៧១.៤.គ នៃវិធានផ្ទៃក្នុង និងដោយយោងតាម សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើការខ្វែងយោបល់របស់ សហព្រះរាជអាជ្ញា ស្របតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង (*ការខ្វែងយោបល់លេខ ០០១/១៨-១១-២០០៨-អវតក/អបជ*)[1] ដែលសហព្រះរាជអាជ្ញា បានទទួលនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី សូមបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ពាក់ព័ន្ធនឹង កងទ័ពបដិវត្តកម្ពុជា (*សំណុំរឿងលេខ ០០៣/២០-១១-២០០៨-អវតក/កសចស*) ដើម្បីសុំឱ្យបើក កិច្ចស៊ើបសួរលើបញ្ហានេះ ។

២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ មានទុកនៅក្នុងសឺមីនានា ដែលមានសឺមីសំខាន់ចំនួន ១ និងសឺមីបន្ទាប់បន្សំចំនួន ៦ ផ្សេងទៀត ។ គ្រប់សឺមីទាំងអស់ មានបិទស្លាករាយឈ្មោះមាតិកា ដែលជាប់នៅនឹងទ្រនុងរបស់វា ។ សឺមីសំខាន់ មានផ្ទុកនូវឯកសារទាំងឡាយ ដូចតទៅ៖

ក. **តារាងទី១៖** ច្បាប់ចម្លងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ដែលបានចុះហត្ថលេខារួចហើយ ជាភាសាអង់គ្លេស ។

ខ. **តារាងទី២៖** ច្បាប់ចម្លងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ដែលបានចុះហត្ថលេខារួចហើយ ជាភាសាខ្មែរ ។

គ. **តារាងទី៣៖ ឧបសម្ព័ន្ធ ក** - បញ្ជីអក្សរកាត់ ដែលប្រើប្រាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ។

ឃ. **តារាងទី៤៖ ឧបសម្ព័ន្ធ ខ** - បញ្ជីរាយឈ្មោះសាក្សី ពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ ។ បញ្ជីឈ្មោះសាក្សីនេះ មានផ្ទុកនូវ៖ ឈ្មោះ-ភេទរបស់សាក្សី និងការ

1

រៀបរាប់អំពីតួនាទីរបស់ពួកគាត់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលការដឹងឮរបស់សាក្សី ជួយបង្ហាញភស្តុតាងអំពីធាតុផ្សំនានា ដែលជាសក្ខីកម្មនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ព្រមទាំងព័ត៌មាន អំពីអាស័យដ្ឋានទំនាក់ទំនងរបស់សាក្សី ។

ង. **តារាងទី៥៖ ឧបសម្ព័ន្ធ គ១** - បញ្ជីរាយឈ្មោះភស្តុតាងមួយ ដែលគាំទ្រចំពោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ។ លិបិក្រមនៃភស្តុតាង មានផ្ទុកនូវព័ត៌មានមូលដ្ឋានអំពីភាពពាក់ព័ន្ធនៃឯកសារនានា ដោយរួមទាំងកាលបរិច្ឆេទឯកសារ, ប្រភេទឯកសារ, ប្រភពឯកសារ, ម្ចាស់អត្ថបទ, ការរៀបរាប់អំពីខ្លឹមសារឯកសារ, និងព័ត៌មានអំពីធាតុផ្សំថាតើ ឯកសារជួយបញ្ជាក់ភស្តុតាងនៅលើធាតុផ្សំណាមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ។

៣. បន្ថែមលើនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ក៏មានអមទៅជាមួយនឹងឯកសារមួយដែលដាក់អក្សរសំគាល់ថា **ឧបសម្ព័ន្ធ គ២** ។ ឧបសម្ព័ន្ធ គ២ នេះ មិនមាននៅក្នុងសឺមីសំខាន់ទាំងនោះទេ ដោយសារថា ឧបសម្ព័ន្ធនេះត្រូវបានបោះពុម្ពនៅលើក្រដាសទំហំ A3 ។ ឧបសម្ព័ន្ធ គ២ គឺគ្រាន់តែជាឯកសារសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះតែប៉ុណ្ណោះ តែមិនមាននៅក្នុងសឺមីណាមួយក្នុងចំណោមសឺមីទាំងអស់នោះទេ ។

៤. ឧបសម្ព័ន្ធ គ២ គឺជាលិបិក្រមរាយឈ្មោះភស្តុតាង ដែលគាំទ្រចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ។ លិបិក្រមនៃភស្តុតាងនេះ មានរាយឈ្មោះឯកសារដដែល ដូចនៅក្នុង ឧបសម្ព័ន្ធ គ១ ហើយប្រើប្រាស់ប្រព័ន្ធលេខរៀងដូចគ្នាដែរ ប៉ុន្តែផ្តល់ព័ត៌មានលំអិតបន្ថែម នៅ លើឯកសារនានា សម្រាប់គោលបំណងនៃការរក្សាទុកជាកំណត់ហេតុ ។ ជាឧទាហរណ៍ ឧបសម្ព័ន្ធ គ២ មានព័ត៌មានអំពី លេខERN ដើម នៃឯកសារ, លេខERNបន្ថែម ដែលពាក់ព័ន្ធ, លេខឯកសាររបស់ DC-Cam (ប្រសិនបើមាន), លេខសំណុំរឿងរបស់ឯកសារ (ប្រសិនបើ មានរួចហើយ នៅក្នុងសំណុំរឿងមួយក្នុងចំណោមសំណុំរឿងនានា), ភាសាដើម, ភាសា បកប្រែណាមួយ, ចំនួនទំព័រសរុបរបស់ឯកសារដើម, លេខទំព័រពាក់ព័ន្ធរបស់ឯកសារ និង ស្ថានភាពនៃការបកប្រែឯកសារ (ថាតើមានសំណើឲ្យមានការបកប្រែហើយ ឬ នៅ) ។ ព័ត៌មាននេះត្រូវបានធ្វើបច្ចុប្បន្នភាពគិតមកដល់ត្រឹមថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយមានកាលបរិច្ឆេទនៃកិច្ចចុះហត្ថលេខាលើដីកាសន្និដ្ឋាននោះ ធ្វើឡើងសហព្រះរាជអាជ្ញាអន្តរជាតិនៅពេលនោះ ។

៥. សំភារៈភស្តុតាងដែលគាំទ្រចំពោះសេចក្តីសន្និដ្ឋាននេះ ត្រូវបានដាក់នៅក្នុងស៊ីឌីបន្ទាប់បន្សំតាមលំដាប់លំដោយ ដែលបានប្រើប្រាស់នៅក្នុងឧបសម្ព័ន្ធ គ១ និង គ២ ។ ប៉ុន្តែ ដើម្បីជាផលប្រយោជន៍នៃប្រសិទ្ធភាព ឯកសារទាំងឡាយណាដែលបានដាក់រួចហើយ នៅលើសំណុំរឿង លេខ ០០១ និង លេខ ០០២ មិនទាន់បានបោះពុម្ពចេញ និងដាក់បញ្ចូលទៅក្នុងស៊ីឌីទេ ដូច្នេះ មានន័យថា៖

(ក) ឯកសារលេខ ១.០១ - ១៥.០១ នៅក្នុងឧបសម្ព័ន្ធ គ១ និង គ២ គឺជាឯកសារថ្មី និងត្រូវបានដាក់នៅក្នុងស៊ីឌី, ហើយនិង

(ខ) ឯកសារលេខ ១៦.០១ - ៣៤.៧៨ នៅក្នុងឧបសម្ព័ន្ធ គ១ និង គ២ គឺជាឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ០០១ ឬ សំណុំរឿង ០០២ និងថាបើដូច្នេះ មិនត្រូវ បានដាក់នៅក្នុងស៊ីឌីទេ ។

៦. ឯកសារទាំងនេះ ត្រូវបានរៀបចំឡើងទៅតាមប្រភេទរបស់វា (ឧទាហរណ៍ ចម្លើយសារភាព របាយការណ៍ កំណត់ហេតុ ទូរលេខ ។ល។) ។ ស៊ីឌីមានទាំងច្បាប់ចម្លងនៃឯកសារដើម និងឯកសារបកប្រែណាមួយដែលស្ថិតនៅក្រោមការកាន់កាប់របស់សហព្រះរាជអាជ្ញាអន្តរជាតិ គិតត្រឹមថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៧. តារាងទាំងឡាយដូចតទៅនេះ មានរៀបរាប់អំពីមាតិការឿងដែលមាននៅក្នុងស៊ីឌីបន្ទាប់បន្សំ ។ ដូចបានកត់សំគាល់ខាងលើ នៅក្នុងស៊ីឌីនីមួយៗ មានដាក់ស្លាកឈ្មោះឯកសារនៅត្រង់ទ្រនុង របស់វា ដែលផ្តល់ព័ត៌មានដូចគ្នានេះ ។

| **សំណុំរឿងលេខ ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស** | | |
|---|---|---|
| **ស៊ីឌីលេខ** | **ឯកសារលេខ** | **ប្រភេទ(ឯកសារ)** |
| ១ | ១.១ –២.៥ | ចម្លើយសារភាពនានា |
| ២ | ១.៦ –១.៧ | ចម្លើយសារភាពនានា |

| | | |
|---|---|---|
| ៣ | ១.៨ – ១.១៤ | ចម្លើយសារភាពនានា |
| ៤ | ២.១ – ៥.២៣ | ចាប់ពីសារាចរណែនាំ រហូតដល់បញ្ជីឈ្មោះផ្សេងៗ |
| ៥ | ៦.១ – ១១.៣ | ចាប់ពីទស្សនាវដ្ដីផ្សេងៗ រហូតដល់ បញ្ជីឈ្មោះអ្នកទោស |
| ៦ | ១២.១ – ១៥.១ | ចាប់ពីរបាយការណ៍នានា រហូតដល់បណ្ដឹងរបស់សាក្សីនានា |

៨. ជាបន្ថែមពីលើសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាច្បាប់ចតចម្លង ព្រមទាំងឯកសារនានា ដែលគាំទ្រសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងនោះ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី អាចមានលទ្ធភាពផ្ដល់ជូនសហចៅក្រមស៊ើបអង្កេតបាន នូវច្បាប់ចម្លងឯកសារគាំទ្រទាំងនោះជាទម្រង់អេឡិចត្រូនិកដោយមានលិបិក្រមព័ត៌មានដែលពាក់ព័ន្ធដែលមាននៅក្នុងឯកសារ CaseMap ផងដែរ បើសិនជាចាំបាច់ ។ សំណុំរឿងនេះ គឺជាកញ្ចក់ដែលឆ្លុះបញ្ចាំងអំពីព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធ **ខ, គ១,** និង **គ២** ។ នៅក្នុងមូលដ្ឋានទិន្នន័យនៃ CaseMap ក៏មានអត្ថបទជាទម្រង់អេឡិចត្រូនិកនៃគ្រប់ឯកសារទាំងអស់ដូចដែលបានលើកឡើងជាសំអាង នៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីផងដែរ ដែលរួមបញ្ចូលទាំងឯកសារផ្សេងៗ ដែលនៅក្នុងសីមីបន្ទាប់បន្សំផង រាប់ទាំងការបកប្រែណាមួយ ព្រមទាំងសេចក្ដីចម្លងឯកសារនានា ក៏ដូចជាឯកសារទាំងឡាយដែលបានលើកឡើងជាសំអាងនៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ០០១ និងលេខ០០២ រួចហើយទៀតផង។

៩. សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី សូមស្នើដល់សហចៅក្រមស៊ើបអង្កេត សុំឱ្យចាប់ផ្ដើមបើកកិច្ចស៊ើបសួរមួយលើបញ្ហានេះនិងសុំឱ្យទទួលភារកិច្ចក្នុងការចាត់វិធានការណ៍ផ្សេងៗដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី១០២ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ | លោក William SMITH<br>**សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី** | ភ្នំពេញ | |